សុន្ទរកថារបស់ **លោក វ៉ាដា តាកាយូគី**

លេខា ផ្នែកសហប្រតិបត្តិការសេដ្ឋកិច្ច និងជំនួយអភិវឌ្ឍន៍ផ្លូវការ

ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា

ថ្លែងក្នុងពិធីសម្ពោធអគារសិក្សាថ្មីនៅសាលាបឋមសិក្សាទួលគ្រោះ ក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់

ថ្ងៃទី ២០ ខែកក្កដា ២០១៥

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ
- សូមគោរព **ឯកឧត្តម ម៉ក់ រ៉ា** អភិបាលរងនៃគណៈអភិបាលខេត្តពោធិ៍សាត់
- សូមគោរព **លោក សួង សុរ៉ុតី** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តពោធិ៍សាត់
- សូមគោរព **អ្នកស្រី កួយ ផល្លានី** នាយកអង្គការកម្ពុជាដើម្បីកុមារ និងការអភិវឌ្ឍន៍ (COCD)
- សូមគោរព ឯកឧត្តម លោកជំទាវ អស់លោក លោកស្រីជាភ្ញៀវកិត្តិយសទាំងអស់!

ថ្ងៃនេះខ្ញុំមានសេចក្តីសោមនស្សរីករាយ ដែលបានមកចូលរួមក្នុងពិធីសម្ពោធអគារសិក្សានៅសាលាបឋមសិក្សាទួលគ្រោះជាមួយនឹងវត្តមានដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តម ម៉ក់ រ៉ា** អភិបាលរងនៃគណៈអភិបាលខេត្តពោធិ៍សាត់ និង**លោក សួង សុរ៉ុតី** ប្រធានមន្ទីរអប់រំ យុវជន និងកីឡាខេត្តពោធិ៍សាត់។ ជាបឋម ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រសួងអប់រំយុវជន និងកីឡា និងជាពិសេស អង្គការ COCD ដែលបានផ្តួចផ្តើមគំនិត និងអនុវត្តគម្រោងនេះយ៉ាងសកម្ម។

ខ្ញុំសូមសម្តែងនូវការកោតសរសើរម្តងទៀត ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការកែលម្អវិស័យអប់រំចាប់តាំងពីសង្គ្រាមផ្ទៃក្នុងត្រូវបានបញ្ចប់។ ដោយទទួលស្គាល់ពីសារៈសំខាន់នៃការអប់រំថាជាកត្តាគន្លឹះសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាពនោះ រដ្ឋាភិបាលជប៉ុន បាននឹងកំពុងបន្តផ្តល់ជំនួយឧបត្ថម្ភរបស់ខ្លួន ដើម្បីគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈគ្រោងការណ៍ជាច្រើនបែបដែលក្នុងនោះក៏មាន គ្រោងការណ៍ជំនួយឥតសំណងជប៉ុនសម្រាប់គម្រោងទ្រង់ទ្រាយតូចហៅកាត់ថាគម្រោងគូសាណូណិ។ សាលាបឋមសិក្សានេះ គឺជាអគារសិក្សាទី៩ ដែលត្រូវបានសាងសង់ដោយគម្រោងគូសាណូណិនៅក្នុងខេត្តពោធិ៍សាត់នេះ។

ខ្ញុំបានទទួលដំណឹងថា សិស្សានុសិស្សប្រមាណជា ១៥០នាក់នៅសាលាបឋមសិក្សាទួលគ្រោះ ត្រូវសិក្សានៅក្នុងថ្នាក់រៀនដែលមានលក្ខណៈចង្អៀត ឬក៏ត្រូវរៀននៅក្រៅថ្នាក់ រីឯសិស្សរៀនថ្នាក់ទី៦ត្រូវទៅរៀននៅសាលាបឋមសិក្សាមួយទៀតដែលនៅឆ្ងាយពីទីនេះ ដោយសារតែកង្វះខាតបន្ទប់រៀន។ សូមបញ្ជាក់ថា ទីតាំងសាលារៀននេះ កាលពីមុនធ្លាប់ជាវាលស្រែដែលមានមីន ប៉ុន្តែឥឡូវបានជំនួសមកវិញដោយអគារសិក្សាថ្មីមួយខ្នងមាន៦បន្ទប់ និងបន្ទប់អនាម័យ ដែលត្រូវបានសាង់សង់ សម្រាប់ក្មួយៗសិស្សានុសិស្សទាំងអស់នៅសាលាបឋមសិក្សាទួលគ្រោះ។

ខ្ញុំសង្ឃឹមថាសិស្សានុសិស្សនៃសាលាបឋមសិក្សាទួលគ្រោះនេះ នឹងអាចសិក្សានៅក្នុងអគារសិក្សាដែលមានបរិស្ថានសិក្សាល្អប្រសើរ ប្រកបដោយសុវត្ថិភាពនិងផាសុខភាព ដូច្នេះសូមក្មួយៗរួមគ្នាជួយថែរក្សាអគារសិក្សានេះអោយបាននៅគង់វង្សល្អ ដើម្បីទុកជានិមិត្តរូបដ៏យូរអង្វែងមួយនៃទំនាក់ទំនងមិត្តភាពរវាង ប្រទេសជប៉ុន និងព្រះរាជាណាចក្រកម្ពុជា។

ជាចុងក្រោយនេះ ខ្ញុំសូមសម្តែងនូវការកោតសរសើរដោយស្មោះសរចំពោះលោក-អ្នកទាំងអស់ដែលបានរួមចំណែកធ្វើអោយគម្រោងនេះដំណើរការទៅបានដោយរលូន។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា កិច្ចសហប្រតិបត្តិការនេះ នឹងជួយពង្រឹងជាបន្តទៅទៀតនូវទំនាក់ទំនងមិត្តភាពរវាងប្រជាជនជប៉ុន និងប្រជាជនកម្ពុជា។

**សូមអរគុណចំពោះការយកចិត្តទុកដាក់ស្តាប់!**